ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ....៣០០១.......អពដ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការកំណត់ពេលធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ចំពោះសហគ្រាសឬក្រុមហ៊ុនស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលសារពើពន្ធ ហើយមិនទាន់បានធ្វើបច្ចុប្បន្នភាព

យោងតាមប្រកាសលេខ ១១៣៩ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៤ ស្តីពីការចុះបញ្ជីពន្ធដារ សហគ្រាស ឬក្រុមហ៊ុនទាំងអស់ត្រូវតែមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដើម្បីផ្តល់លទ្ធភាពឱ្យអគ្គនាយកដ្ឋានពន្ធដាររៀបចំប្រព័ន្ធទិន្នន័យមួយក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ Database ក្នុងន័យជួយសម្រួលដល់ការផ្តល់សេវាជូនអ្នកជាប់ពន្ធបានល្អនិងការប្រមូលពន្ធឱ្យបានត្រឹមត្រូវប្រកបដោយតម្លាភាព។ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូន លោក-លោកស្រី ជាប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាល ឬម្ចាស់សហគ្រាស ដែលមានសហគ្រាសឬក្រុមហ៊ុន ដែលចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារទាំងអស់មេត្តាជ្រាបថា អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា ក្នុងរយៈពេលជាង ១៦ខែកន្លងមកដោយគិតចាប់ពីកាលបរិច្ឆេទនៃការចេញប្រកាសលេខ ១១៣៩ មានសហគ្រាសឬក្រុមហ៊ុនដែលបានចុះបញ្ជីពន្ធដារជាច្រើនបានមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ហើយក៏នៅមានសហគ្រាសឬក្រុមហ៊ុនមួយចំនួនទៀតនៅមិនទាន់បានមកបំពេញកាតព្វកិច្ចធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសនៅឡើយ ដោយហេតុថាមានសហគ្រាសឬក្រុមហ៊ុនទាំងនោះកំពុងមមាញឹករៀបចំឯកសារ ឬប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាល ឬម្ចាស់សហគ្រាស ជាប់រវល់នៅក្រៅប្រទេសមិនទាន់មានពេលមកថតរូប និងស្កេនមេដៃ។

អាស្រ័យហេតុនេះ អគ្គនាយកដ្ឋានពន្ធដារសម្រេចកំណត់កាលបរិច្ឆេទនៃការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ឬក្រុមហ៊ុនទាំងអស់ត្រឹម ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ដើម្បីផ្តល់លទ្ធភាពជូនសហគ្រាសឬក្រុមហ៊ុនមួយចំនួន ដែលមិនទាន់បានមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសមានពេលវេលាគ្រប់គ្រាន់ ក្នុងការមកធ្វើបច្ចុប្បន្នភាពព័ត៌មាននេះ។

១. សម្រាប់សហគ្រាស ឬក្រុមហ៊ុន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ លោក-លោកស្រី ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាល ឬម្ចាស់សហគ្រាសទាំងអស់ អាចមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំនៃអគ្គនាយកដ្ឋានពន្ធដារ ឬការិយាល័យចុះបញ្ជី/ក្រុមការងារចុះបញ្ជីពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារដែលស្ថិតនៅសាលាជាតិពន្ធដារ (ជាន់ទី ៦) អគារលេខ ៤១-៤៣ ផ្លូវ ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ខាងកើតអគ្គនាយកដ្ឋានពន្ធដារ)

២. សម្រាប់សហគ្រាស ឬក្រុមហ៊ុន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខេត្ត-ខណ្ឌ លោក-លោកស្រី ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាល ឬម្ចាស់សហគ្រាសទាំងអស់ អាចមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសនៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬការិយាល័យចុះបញ្ជី/ក្រុមការងារចុះបញ្ជីពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារដែលស្ថិតនៅសាលាជាតិពន្ធដារ (ជាន់ទី ៦)

លោក-លោកស្រីអាចទំនាក់ទំនងសាកសួរព័ត៌មានអំពីការធ្វើបច្ចុប្បន្នភាពព័ត៌មាន នៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ បន្ទប់នៃក្រុមការងារចុះបញ្ជីពន្ធដារ សាខាពន្ធដារខេត្ត-ខណ្ឌនីមួយៗតាមរយៈឈ្មោះ លេខទូរស័ព្ទ និងអ៊ីមែលដែលមានភ្ជាប់មកជាមួយ។

ក្នុងករណីសហគ្រាសឬក្រុមហ៊ុន មិនបានមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសតាមកាលបរិច្ឆេទកំណត់ខាងលើនេះ អគ្គនាយកដ្ឋានពន្ធដារនឹង ទុកជាមោឃៈឬព្យួរវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ដែលបានចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

ឆ្នាំ២០១៤ (វិញ្ញាបនបត្រអាករលើតម្លៃបន្ថែមតាមប្រព័ន្ធចាស់) ហើយនៅពេលដែលទុកជាមោឃៈឬព្យួរនូវវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម សហគ្រាស ឬក្រុមហ៊ុនអស់លោក-លោកស្រី៖

- មិនអនុញ្ញាតឱ្យស្នើសុំជាឥណទានយោងអាករលើធាតុចូល ឬស្នើសុំបង្វិលសងប្រាក់អាករលើតម្លៃបន្ថែមឡើយ
- មិនអាចនាំចេញនាំចូលបាន ដោយអគ្គនាយកដ្ឋានពន្ធដារសហការជាមួយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបញ្ឈប់ប្រតិបត្តិការនាំចេញ- នាំចូល
- សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផ្អាកការពិនិត្យសំណើសុំនាំចូលវត្ថុធាតុដើម គ្រឿងម៉ាស៊ីន និងសម្ភារបរិក្ខារ
- សហការជាមួយក្រសួងឬស្ថាប័នពាក់ព័ន្ធឱ្យព្យួរ ឬលុបចោល ឬមិនអនុញ្ញាតឱ្យបន្តសុពលភាពអាជ្ញាប័ណ្ណ និង
- វិធានការផ្សេងៗទៀតតាមច្បាប់ជាធរមាន

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា ក្នុងអំឡុងពេលនៃការកំណត់កាលបរិច្ឆេទខាងលើ សូម លោក-លោកស្រី ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាល ឬម្ចាស់សហគ្រាសទាំងអស់ មេត្តារួសរាន់មកធ្វើបច្ចុប្បន្នព័តិមានសហគ្រាសឱ្យបានទាន់ពេលវេលា និងបានគ្រប់ៗសហគ្រាសឬក្រុមហ៊ុនតាមការកំណត់ជាក់ជាមិនខាន។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

**សម្រាប់ព័ត៌មានបន្ថែម**

**ស្តីពី**

**បច្ចុប្បន្នភាពព័ត៌មានសហគ្រាសសូមទំនាក់ទំនងដូចខាងក្រោម ÷**

| | ឈ្មោះ | ទូរស័ព្ទ | អ៊ីមែល |
|---|---|---|---|
| ១. | ក្រុមការងារចុះបញ្ជីនៃអគ្គនាយកដ្ឋានពន្ធដារ | | |
| | ១. លោក ខែន គីម | ០១៧ ៩៣៩ ៣៩០ | khemkim@tax.gov.kh |
| | ២. លោក កៅ វិច្ឆិកា | ០១២ ៦៣២ ២៨៧ | kaovicheka@tax.gov.kh |
| ២. | នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ | | |
| | ១. លោក ស៊ាង សុធារ៉ា | ០១២ ៨៩៥ ៦០៦ | seangsotheara@tax.gov.kh |
| ៣. | សាខាពន្ធដារខណ្ឌចំការមន | | |
| | ១. លោក ចាន់ ធឿន | ០៨៥ ២៦៧ ៧៧៧ | chanthoeun@tax.gov.kh |
| | ២. លោកស្រី ឈុត យុទ្ធារី | ០៧៧ ៤៧១ ៣៣៦ | chhuthyutheary@tax.gov.kh |
| | ៣. លោកស្រី ចែត្រ សុផានារី | ០៧៧ ៦០២ ៦៧៨ | chetsophaneary@tax.gov.kh |
| ៤. | សាខាពន្ធដារខណ្ឌទួលគោក | | |
| | ១. លោក ទឹម បាណា | ០១២ ៩៨៩ ១៩១ | timbana@tax.gov.kh |
| | ២. កញ្ញា ឈឿង ពិសី | ០១០ ៥៤៣ ៥៩៩ | chhoeungpisey@tax.gov.kh |
| ៥. | សាខាពន្ធដារខណ្ឌដូនពេញ | | |
| | ១. លោកស្រី គាន រ៉ាមី | ០១១ ៨៧៧ ៣២៨ | keanramy@tax.gov.kh |
| | ២. លោក ស៊ុម ច័ន្ទមុន្នី | ០៩២ ៩៣៩ ៤៩១ | sumchanmony@tax.gov.kh |
| | ៣. លោក ប៉ែន សុជាតា | ០៨៦ ២៨២ ៧២៦ | pensocheata@tax.gov.kh |
| ៦. | សាខាពន្ធដារខណ្ឌឫស្សីកែវ | | |
| | ១. លោក ជិន ហាប់ | ០១២ ៨៦៦ ៦៩០ | chinhap@tax.gov.kh |
| | ២. លោក អ៊ុង សុវិទ្យា | ០៩៩ ៨៥៥ ៨០០ | ungsovithiea@tax.gov.kh |
| | ៣. លោក សួន សិលា | ០១៧ ៣៧០ ៦០៦ | sounseila@tax.gov.kh |
| ៨. | សាខាពន្ធដារខណ្ឌ៧មករា | | |
| | ១. លោកស្រី ឆាំ ម៉ារិត | ០១១ ៧៣៥ ៩០៦ | chhammarith@tax.gov.kh |
| | ២. លោក មាស ថុល | ០១៦ ៧៨៣ ៣៨៣ | measthol@tax.gov.kh |
| | ៣. លោកស្រី ងី ស៊ីណាត | ០១២ ៨៩៦ ១២២ | ngysinath@tax.gov.kh |
| ៩. | សាខាពន្ធដារខណ្ឌមានជ័យ | | |
| | ១. លោក ឆាយ សុភ័ក្តិ | ០៧៦ ២៧៧ ៩៩៩៩ | chhaysopheak@tax.gov.kh |
| | ២. លោកស្រី អ៊ឹង បុប្ផា | ០១២ ៨០៦ ១២៤ | ingbopha@tax.gov.kh |
| ១០. | សាខាពន្ធដារខណ្ឌដង្កោ | | |
| | ១. លោក ហុង ឫទ្ធី | ០១២ ៩៧៧ ៥១០ | hongrithy@tax.gov.kh |
| | ២. លោក សៀន ដួងវាសនា | ០៨៩ ៧៧៧ ៥៥១ | seandoungveasna@tax.gov.kh |
| ១១. | សាខាពន្ធដារខណ្ឌសែនសុខ | | |
| | ១. លោកស្រី សៅ សម្បត្តិចន្ទីណា | ០១៧ ៩២៧ ៧៩១ | saosambatchantina@tax.gov.kh |
| | ២. លោក បាន សំអាង | ០៧៧ ៨៩៤ ០០៧ | bansamang@tax.gov.kh |
| ១២. | សាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ | | |
| | ១. លោក ទ្រី សុភី | ០១២ ៣៨៧ ៩៦៣ | trysophy@tax.gov.kh |
| | ២. លោក ប៉ុក ផល្លា | ០១២ ៨៣៨ ៣៤៨ | pokphalla@tax.gov.kh |

| | | | |
|---|---|---|---|
| ១៣. សាខាពន្ធដារខេត្តកណ្តាល | | | |
| | ១. លោក ឆឹង វណ្ណឌី | ០៨៩ ៣៦៣ ៦៨៨ | chhoeungvanndy@tax.gov.kh |
| | ២. លោក ចំរើន សុភក្រ | ០១២ ៦៣៦ ២៩៩ | chamroeunsopheak@tax.gov.kh |
| | ៣. លោក សួង រ៉ាត់ | ០១៦ ២៣៤ ២៣៤ | soungrath@tax.gov.kh |
| ១៤. សាខាពន្ធដារខេត្តកំពង់ចាម | | | |
| | ១. លោក ម៉ែន ប៊ុនធឿន | ០១៧ ៨០០ ៨៥៨ | menbunthoeun@tax.gov.kh |
| | ២. លោក ងួន លាងឈុន | ០១២ ៥៨៤ ២៥៣ | ngounleangchhun@tax.gov.kh |
| ១៥. សាខាពន្ធដារខេត្តបាត់ដំបង | | | |
| | ១. ទូច សុទ្ធី | ០១២ ៤៣២ ០៩៩ | touchsothy@tax.gov.kh |
| | ២. សារ៉ាន រតនា | ០៨៩ ៨៣៦ ០០៦ | saranrattana@tax.gov.kh |
| | ៣. ថា ប៊ុនធឿន | ០៨៩ ៩៧៨ ៩៧៧ | thabuntheoun@tax.gov.kh |
| | ៤. លាង កែវពេជ្រនាថ | ០១០ ៨៤៤ ៧៥៦ | leangkeopecknert@tax.gov.kh |
| | ៥. សេង សុភក្តិ | ០៧៧ ២៦៥ ៧៥៧ | sengsopheak@tax.gov.kh |
| ១៦. សាខាពន្ធដារខេត្តព្រៃវែង | | | |
| | ១. លោក សំ សារ៉ាវុធ | ០១៧ ៤២៧ ១៩៤ | samsaravuth@tax.gov.kh |
| | ២. លោក សុត សៅបាន | ០៩៦ ២៧៩ ៧៧៧៩ | sotsaoban@tax.gov.kh |
| ១៧. សាខាពន្ធដារខេត្តសៀមរាប | | | |
| | ១. លោក អាង រ៉ាស៊ី | ០១២ ៩៥៣ ៤៣៧ | angrasy@tax.gov.kh |
| | ២. លោក សៀ ម៉េងសុវិសាល | ០១២ ៦៩៣ ៩៩០ | searmengsokvisal@tax.gov.kh |
| ១៨. សាខាពន្ធដារខេត្តកំពង់ធំ | | | |
| | ១. គង់ សារ៉ាយ | ០១២ ៦៣១ ៣៨៥ | kongsaray@tax.gov.kh |
| | ២. ហ៊ុន ទនសុទ្ធា | ០១៧ ៨៥៧ ៥៧១ | huntornsothea@tax.gov.kh |
| ១៩. សាខាពន្ធដារខេត្តតាកែវ | | | |
| | ១. លោក មែន ស៊ីណាត | ០១១៥១១៥៧១ | mensinath@tax.gov.kh |
| | ២. លោក ឡុង សុបញ្ញា | ០៩២ ៧១៩៦៨៦ | longsopanha@tax.gov.kh |
| ២០. សាខាពន្ធដារខេត្តស្វាយរៀង | | | |
| | ១. ម៉ៅ ទិន | ០៩២ ៦៣៦ ៦០២ | maotin@tax.gov.kh |
| | ២. តុប សាភឿន | ០៩៦ ៤៣៣ ៣៣៧១ | tobsaphoeurn@tax.gov.kh |
| ២១. សាខាពន្ធដារខេត្តពោធិ៍សាត់ | | | |
| | ១. សំ វណ្ណា | ០៧៨ ៨៤៨ ៧៤៨/០៩៣ ៨៩៥ ២៨៨ | samvanna@tax.gov.kh |
| | ២. ម៉ម ប៊ុនផាត | ០៩៦ ៣៤៩ ៩៩៥៦/០៨៩ ៦១១ ២៣០ | mombonpat@tax.gov.kh |
| ២២. សាខាពន្ធដារខេត្តកំពង់ឆ្នាំង | | | |
| | ១. លោក កែវ ច័ន្ទណារុន | ០១២ ៣៧៧ ៨៤០ | keochannarun@tax.gov.kh |
| | ២. លោក ឆាយ បូណា | ០៩៦ ៥៥៦ ៨៤៩៦ | chhaybona@tax.gov.kh |
| ២៣. សាខាពន្ធដារខេត្តកំពង់ស្ពឺ | | | |
| | ១. លោក ប៉ែន សុវណ្ណថាវរិទ្ធ | ០១៧ ៨៨៧ ៧១២ | pensovanthavrith@tax.gov.kh |
| | ២. កញ្ញា សាយ មួយគា | ០៧៧ ៨៥៩ ៤១៩ | saymouykea@tax.gov.kh |
| ២៤. សាខាពន្ធដារខេត្តកំពត | | | |
| | ១. លោក គង់ សុវ៉ាត | ០១២ ៣៣០ ១៣២ | kongsavath@tax.gov.kh |
| | ២. លោក ណុប ទិត្យតុលា | ០៩៧ ៧៩៧ ៧១៦៦ | noptithtola@tax.gov.kh |

| | | | |
|---|---|---|---|
| **២៥. សាខាពន្ធដារខេត្តព្រះសីហនុ** | | | |
| | ១. លោក ហ្វា សំផន | ០១៦ ៦៨៦ ៨៤០ | hoasamphan@tax.gov.kh |
| | ២. លោក ឃាង ប្រពៃ | ០១៥ ៦៩២ ២៧៧ | kheangprapey@tax.gov.kh |
| **២៦. សាខាពន្ធដារខេត្តកោះកុង** | | | |
| | ១. សឿម ធីតា | ០១៦ ៨៥៣ ៤២៥ | soeumthida@tax.gov.kh |
| | ២. អ៊ឹង ស៊ | ០១៦ ៨៩៩ ៤៧៦ | eungsor@tax.gov.kh |
| **២៧. សាខាពន្ធដារខេត្តព្រះវិហារ** | | | |
| | ១. លោក ម៉ុល ប៉ូរិន | ០១៧ ៤៤៥ ៧៥៥ | molborin@tax.gov.kh |
| | ២. លោក ជិន វិច្ចិកា | ០៩៣ ៤៤២ ២២២ | chinvichika@tax.gov.kh |
| **២៨. សាខាពន្ធដារខេត្តក្រចេះ** | | | |
| | ១. លោក សៀន តុលា | ០១២ ៤២៦ ៥៩៩ | seantola@tax.gov.kh |
| | ២. លោក មួក សុខរីណា | ០៧៧ ៨៩៣ ១១៣ | mouksokrina@tax.gov.kh |
| **២៩. សាខាពន្ធដារខេត្តរតនគិរី** | | | |
| | ១. ជុំ តុល | 089 634 006 | chumtol@tax.gov.kh |
| **៣០. សាខាពន្ធដារខេត្តមណ្ឌលគិរី** | | | |
| | ១. ង៉ែត គីមរ៉េត | ០៩៧ ៦៦៨ ៣៣០១ | ngethkimreth@tax.gov.kh |
| | ២. ចេវ សុជា | ០៩៧ ៦៥០ ៨១៤៥ | chevsochea@tax.gov.kh |
| | ៣. សោ បឿន | ០៩៨ ៨២៥ ០០៤ | sauboeun@tax.gov.kh |
| **៣១. សាខាពន្ធដារខេត្តបន្ទាយមានជ័យ** | | | |
| | ១. លោក វ៉ាន់ បូរ៉ា | ០១២ ៩៨៣ ២២០/០៩៦ ២២៩ ៣៧៧២ | vannbora@tax.gov.kh |
| | ២. លោក ទូច ច័ន្ទរដ្ឋា | ០៧៧ ៣១៨ ១៥៥ | touchchanrotha@tax.gov.kh |
| **៣២. សាខាពន្ធដារខេត្តស្ទឹងត្រែង** | | | |
| | ១. លោក ហោ សុមេធ | ០៧៧ ៥៥៥៣៦៣ | horsometh@tax.gov.kh |
| | ២. លោក មាស គីមហន | ០១២ ៦២៦ ៩៦៥ | measkimhorn@tax.gov.kh |
| **៣៣. សាខាពន្ធដារខេត្តកែប** | | | |
| | ១. លោក វៀម វិត | ០១២ ៩១០ ១១៨ | eamvith@gdt.gov.kh |
| | ២. លោក គង់ ដារ៉េត | ០៩២ ៩៨០ ៤៦២ | kongdaret@gdt.gov.kh |
| **៣៤. សាខាពន្ធដារខេត្តប៉ៃលិន** | | | |
| | ១. កញ្ញា ណុប ផល្លា | ០៩៦ ៧៨០ ៥៣៩១ | nobphalla@tax.gov.kh |
| | ២. លោក កើត សំរេច | ០៩៧ ៧៣៦ ៤៥២៧ | koetsamrach@tax.gov.kh |
| **៣៥. សាខាពន្ធដារខេត្តឧត្តរមានជ័យ** | | | |
| | ១. លោក ឃឹម លាង | ០១០ ៥៨២ ១៦៨ | khimleang@tax.gov.kh |
| | ២. លោក រ៉ុង សារេន | ០៦៩ ៧០០ ៩៦២ | rongsaren@tax.gov.kh |
| | ៣. លោក ម៉ឹង សោភ័ណ្ឌ | ០១០ ៨៨២ ៥៩៤ | moeungsophorn@tax.gov.kh |
| **៣៦. សាខាពន្ធដារខេត្តត្បូងឃ្មុំ** | | | |
| | ១. លោក ស៊ុន សុផុន | ០៧៨ ៧៦៦ ៦៦២ | sunsophon@tax.gov.kh |
| | ២. លោក អ៊ុច ចាន់ពិសិដ្ឋ | ០១០ ៤៧៤ ៤៧៣ | uchchanpiseth@tax.gov.kh |
| | ៣. លោក ជិន វឌ្ឍនា | ០១១ ៥៧៩ ០០០ | chinvathana@tax.gov.kh |